ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ៤៦ ត្រីមាសទី០២ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៨-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦២៣ ស្តីពី ការបញ្ចប់ និងតែងតាំងមុខតំណែងឯកឧត្តម **សុខ ខឿន** នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសិង្ហបុរី ចូលប្រទេស ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំងមុខតំណែង ជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់កុងស៊ុល និងព្រំដែន ជំនួសឯកឧត្តម **ឌូ សំណាង** ដែលទទួលភារកិច្ចថ្មី និងតែងតាំងមុខតំណែងឯកឧត្តម **ហ៊ុន ហាន** នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ បច្ចុប្បន្នអគ្គលេខាធិការ នៃលេខាធិការដ្ឋាន ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសិង្ហបុរី ជំនួសវិញ | ៥៥១៧ |
| ៨-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦២៤ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ពេជ្រឃុន បញ្ញា** នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធរុស្ស៊ី សាធារណរដ្ឋបេឡារុស្ស និងសាធារណរដ្ឋអាមេនី ដែលមាននិវេសនដ្ឋាននៅទីក្រុងម៉ូស្គូ ចូលប្រទេស ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំងមុខតំណែងឯកឧត្តម **អៀម ពុទ្ធិរោ** នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ បច្ចុប្បន្នអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធរុស្ស៊ី សាធារណរដ្ឋបេឡារុស្ស និងសាធារណរដ្ឋអាមេនី ដែលមាននិវេសនដ្ឋាននៅទីក្រុងម៉ូស្គូ ជំនួសវិញ | ៥៥១៩ |
| ៨-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦២៥ ស្តីពី ការបញ្ចប់មុខតំណែងពីសមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ៤រូប និងតែងតាំងនិងផ្តល់ឋានៈដល់សមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ៤រូប | ៥៥២១ |
| ១០-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦២៦ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌដល់លោក **ទី ចាន់ចំរើន** នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៥៥២៣ |
| ១០-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦២៧ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលបានទទួលមរណភាព ចំនួន ៣រូប | ៥៥២៥ |
| ១០-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦២៨ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍តាមអាយុកំណត់ដល់លោក **ចាន់ គេចសាយ** នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥៥២៧ |
| ១០-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦២៩ ស្តីពី ការតាំងស៊ប់នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដល់មន្ត្រីរាជការ ៣រូប | ៥៥២៩ |
| ១០-៦-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦៣០ ស្តីពី ការបញ្ចូល និងតាំងស៊ប់ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះមន្ត្រីរាជការ ១៣រូប | ៥៥៣១ |

១២-៦-២០២៦ -ព្រះរាជក្រឹត្យ នស/រកត/០៦២៦/៦៣១ ស្ដីពី ការតែងតាំងឯកឧត្តម **ពិន សុផល** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ដោយពុំទទួលប្រាក់បំណាច់មុខងារ ៥៥៣៣

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៩-៥-២០២៦ -អនុក្រឹត្យលេខ ៩២ អនក្រ.បក ស្ដីពី ការធ្វើអនុប្បយោគ ៥៥៣៤

១៩-៥-២០២៦ -អនុក្រឹត្យលេខ ៩៣ អនក្រ.បក ស្ដីពី ការកំណត់តំបន់ប្រើប្រាស់ដោយចីរភាពនិងការធ្វើអនុប្បយោគ លើផ្ទៃដីទំហំ ៣២ហិកតា ៣៤អា (សាមសិបពីរហិកតាសាមសិបបួនអា) ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំព្រេចនិងដែនជម្រកសត្វព្រៃកែវសីមា ភូមិសាស្ត្រខេត្តមណ្ឌលគិរី ៥៥៣៦

២០-៥-២០២៦ -អនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្ដីពី ការបង្កើតគណៈកម្មាធិការសម្របសម្រួលការងារ របស់ក្រសួង ស្ថាប័ន ជាមួយអង្គការសង្គមស៊ីវិល ៥៥៣៩

២០-៥-២០២៦ -អនុក្រឹត្យលេខ ៩៥ អនក្រ.បក ស្ដីពី ការបង្កើតមូលនិធិកីឡាជនពិការ តេជោសែន ៥៥៤៥

២០-៥-២០២៦ -អនុក្រឹត្យលេខ ៩៦ អនក្រ.បក ស្ដីពី សេវាអត្តសញ្ញាណកម្ម ដែលមិនតម្រូវឱ្យបង់កម្រៃសេវា និងតម្រូវឱ្យបង់កម្រៃសេវា ៥៥៥២

២១-៥-២០២៦ -អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្ដីពី ទិវាជាតិប្រជាជន ៥៥៥៨

២១-៥-២០២៦ -អនុក្រឹត្យលេខ ១០០ អនក្រ.បក ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិយូណេស្កូកម្ពុជា ៥៥៦០

២០-៥-២០២៦ -អនុក្រឹត្យលេខ ៤៤២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៥៦៤

២០-៥-២០២៦ -អនុក្រឹត្យលេខ ៤៤៣ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៥៥៦៩

២១-៥-២០២៦ -អនុក្រឹត្យលេខ ៤៤៤ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៥៥៧១

២១-៥-២០២៦ -អនុក្រឹត្យលេខ ៤៤៥ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៥៧៣

២១-៥-២០២៦ -អនុក្រឹត្យលេខ ៤៤៦ អនក្រ.តត ស្ដីពី ការតែងតាំងអគ្គនាយក នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" អាណត្តិទី៩ ៥៥៧៥

២១-៥-២០២៦ -អនុក្រឹត្យលេខ ៤៤៧ អនក្រ.តត ស្ដីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" អាណត្តិទី៩ ៥៥៧៧

២១-៥-២០២៦ -អនុក្រឹត្យលេខ ៤៤៨ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៥៧៩

២១-៥-២០២៦ -អនុក្រឹត្យលេខ ៤៤៩ អនក្រ.តត ស្ដីពី ការបង្គាប់ឱ្យធ្វើបត្យាប័ន ៥៥៨១

២២-៥-២០២៦ -អនុក្រឹត្យលេខ ៤៥៣ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៥៨៣

២៥-៥-២០២៦ -អនុក្រឹត្យលេខ ៤៥៤ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៥៨៥

២៥-៥-២០២៦ -អនុក្រឹត្យលេខ ៤៥៥ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៥៨៧

២៥-៥-២០២៦ -អនុក្រឹត្យលេខ ៤៥៦ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៥៨៩

២៥-៥-២០២៦ -អនុក្រឹត្យលេខ ៤៥៧ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៥៩១

២៥-៥-២០២៦ -អនុក្រឹត្យលេខ ៤៥៨ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៥៩៣

២៥-៥-២០២៦ -អនុក្រឹត្យលេខ ៤៥៩ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៥៩៥

២៥-៥-២០២៦ -អនុក្រឹត្យលេខ ៤៦០ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥៥៩៧

| | | |
|---|---|---|
| ២៥-៥-២០២៦ | -អនុក្រឹត្យលេខ ៤៦១ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ | ៥៥៩៩ |
| ២៥-៥-២០២៦ | -អនុក្រឹត្យលេខ ៤៦២ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ | ៥៦០១ |
| ២៥-៥-២០២៦ | -អនុក្រឹត្យលេខ ៤៦៣ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ | ៥៦០៣ |
| ២៥-៥-២០២៦ | -អនុក្រឹត្យលេខ ៤៦៤ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ | ៥៦០៥ |
| ២៥-៥-២០២៦ | -អនុក្រឹត្យលេខ ៤៦៥ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ | ៥៦០៧ |
| ២៥-៥-២០២៦ | -អនុក្រឹត្យលេខ ៤៦៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ | ៥៦០៩ |
| ២៥-៥-២០២៦ | -អនុក្រឹត្យលេខ ៤៦៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ៥៦១១ |
| ២៥-៥-២០២៦ | -អនុក្រឹត្យលេខ ៤៦៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ៥៦១៣ |

## ២~សេចក្តីសម្រេច

| | | |
|---|---|---|
| ២៥-៥-២០២៦ | -សេចក្តីសម្រេចលេខ ៦២ សសរ ស្តីពី ការចាត់តាំងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | ៥៦១៥ |
| ២៦-៥-២០២៦ | -សេចក្តីសម្រេចលេខ ៦៣ សសរ ស្តីពី ការបង្កើតក្រុមការងារយុទ្ធសាស្ត្រជាតិបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០២៦-២០៣០ | ៥៦១៧ |
| ២៨-៥-២០២៦ | -សេចក្តីសម្រេចលេខ ៦៥ សសរ ស្តីពី ការតែងតាំងបន្ថែមសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ៥៦២១ |

## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

| | | |
|---|---|---|
| ១៧-១២-២០២៥ | -ប្រកាសអន្តរក្រសួងលេខ ១០៣៨ សហវ.ប្រក.អរតន ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់និងភ្នាក់ងារបើកផ្តល់ជំនួស សម្រាប់បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ជូនមន្ត្រីរាជការប្រចាំនៅអគ្គាធិការដ្ឋាន នៃក្រសួងមុខងារសាធារណៈ | ៥៦២៣ |

### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| | | |
|---|---|---|
| ៤-៦-២០២៦ | -សេចក្តីសម្រេចលេខ ១១៥ ឧវបន.អវបន.សសរ ស្តីពី ការតែងតាំងនាយកប្រតិបត្តិនៃអង្គភាពប្រតិបត្តិនៃមូលនិធិស្រាវជ្រាវជាតិ | ៥៦២៦ |
| ៤-៦-២០២៦ | -សេចក្តីសម្រេចលេខ ១១៦ ឧវបន.អវបន.សសរ ស្តីពី រូបសញ្ញានិងត្រារបស់មូលនិធិស្រាវជ្រាវជាតិ | ៥៦២៨ |

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៦៤៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** បញ្ចប់ និងតែងតាំងមុខតំណែងឯកឧត្តម **សុខ ឌឿន** អត្តលេខ ១៧៩២១០០២៤២ ឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៣ នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសិង្ហបុរី ចូលប្រទេស ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំងមុខតំណែង ជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន ជំនួសឯកឧត្តម ជូ សំណាង ដែលទទួលភារកិច្ចថ្មី។

**មាត្រា ២:** តែងតាំងមុខតំណែងឯកឧត្តម **ហ៊ុន ហាន** អត្តលេខ ១៧២០៨០០១០៦ ឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៤ នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ បច្ចុប្បន្នអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសិង្ហបុរី ជំនួសវិញ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣:** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពរស. ២៦០៦. ៦៣៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៦៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: បញ្ចប់មុខតំណែងឯកឧត្តម **ពេជ្រឃុន បញ្ញា** អត្តលេខ ១៧៣១២០០១៥៣ ឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៣ នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធរុស្ស៊ី សាធារណរដ្ឋបេឡារុស្ស និងសាធារណរដ្ឋអាមេនី ដែលមាននិវេសនដ្ឋាននៅទីក្រុងម៉ូស្គូ ចូលប្រទេស ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា ២**: តែងតាំងមុខតំណែងឯកឧត្តម **អៀម ពុទ្ធិរោ** អត្តលេខ ១៧១២១០០០៣៩ ឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ៣ នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់ បច្ចុប្បន្នអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធរុស្ស៊ី សាធារណរដ្ឋបេឡារុស្ស និងសាធារណរដ្ឋអាមេនី ដែលមាននិវេសនដ្ឋាននៅទីក្រុងម៉ូស្គូ ជំនួសវិញ។

**មាត្រា ៣:** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស.រកត.០៦២៦.៦៣៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៣៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៦៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣៤៨ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ស្តីពីការតែងតាំងនិងផ្តល់ឋានៈដល់សមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** បញ្ចប់មុខតំណែងពីសមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ៤ រូបៈ

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឯម សុជាតិ** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២- ឯកឧត្តម | **ធឹម សាលួត** | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម | **ស៊ិន សុខគារ** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៤- ឯកឧត្តម | **សុខ ឥន្ទ្រា** | មានឋានៈស្មើ អគ្គនាយក។ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២** : តែងតាំងនិងផ្តល់ឋានៈដល់សមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ៤ រូបៈ

១-លោកជំទាវ **សែម ដាលិកា** មានឋានៈស្មើ រដ្ឋមន្ត្រី
២-ឯកឧត្តម **ចក់ រ៉ា** មានឋានៈស្មើ រដ្ឋលេខាធិការ
៣-លោកជំទាវ **ឃី ឆច័ន្ទ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៤-លោកជំទាវ **ឃៀង ធីតា** មានឋានៈស្មើ អគ្គនាយក។

**មាត្រា៣** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០២៦
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

នស.រកត.០៦២៦.៦៣៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/២៤២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌដល់លោក **រី ចាន់ចំរើន** ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាប់ពីថ្ងៃទី **១៤** ខែ**កុម្ភៈ** **ឆ្នាំ២០២៦**។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី*១០* ខែ *មិថុនា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

*រ.ស.ម. ៣៦០៦. ៦៣៥*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៦៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤ /១១៦៩ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤ /១៤៧៧ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលបានទទួលមរណភាព ៖

**ក. ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក**

១. ឧត្តមសេនីយ៍ទោ **ឌុយ សាម៉េត** អត្តលេខ ០០១៥៧៣

២. ឧត្តមសេនីយ៍ទោ **ភើត ស៊ីយុត្តិ** អត្តលេខ ០០៨៥៤២

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ខ-ថ្នាក់ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

-ឧត្តមសេនីយ៍ត្រី **ថាច់ គួន** អត្តលេខ ០០១៦៥៦

**មាត្រា២**: សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *១០* ខែ *មិថុនា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

*ពរស. ៤២០៦. ៦៣៦*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/[illegible]

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដាក់ឱ្យចូលនិវត្តន៍តាមអាយុកំណត់ដល់លោក **ចាន់ អេងសាយ** អត្តលេខ **១៦៦០៨០០៤៩៥** ក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ **៦** នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីថ្ងៃទី**១០** ខែ**ឧសភា** ឆ្នាំ២០២៦។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *១០* ខែ *ឧសភា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

*នស. ៥២០៦. ៦៣៧*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៦៤៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ត្រាស់បង្គាប់

**មាត្រា១ :** តាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដល់មន្ត្រីរាជការ **០៣ រូប** ចាប់ពីថ្ងៃទី**១៩** ខែ**មីនា** ឆ្នាំ២០២៦៖

១-លោក **ស៊ុនសី សិរីវិរៈទេព** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

២-លោក **ប្រាក់ ច័ន្ទវីរៈសត្យា** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

៣-លោក **គង លឹមពេជ្ររតនៈ** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *១០* ខែ *មីនា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

*ពរស. ៥២០៦. ៦៣៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/៦៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៨៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៤២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៩ មាត្រា១៣ មាត្រា១៨ មាត្រា២២ មាត្រា២៤ មាត្រា៣២ និងមាត្រា៥១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ត្រាស់បង្គាប់

**មាត្រា១** : បញ្ចូល និងតាំងស៊ប់ ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះមន្ត្រីរាជការ **១៣ រូប** :

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | កម្រិតសញ្ញាបត្រ | ឋានន្តរស័ក្តិ និងថ្នាក់ |
|---|---|---|---|---|---|
| ១ | ងួន ចរិយា | ស | ១០-១១-១៩៨២ | បណ្ឌិត | អនុមន្ត្រី ថ្នាក់លេខ៤ |
| ២ | ចន្ទ ទិត្យ | ប | ១៤-០៧-២០០២ | បរិញ្ញាបត្រជាន់ខ្ពស់ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ៣ | ម៉ម សុខុម | ស | ១១-០២-១៩៨៨ | បរិញ្ញាបត្រជាន់ខ្ពស់ | អនុមន្ត្រី ថ្នាក់លេខ៤ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | | | |
|---|---|---|---|---|---|
| ៤ | លឹម ផាន់ណា | ស | ០៦-០៧-១៩៩០ | បរិញ្ញាបត្រជាន់ខ្ពស់ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ៥ | ហេង មួយខេង | ស | ៣០-១២-១៩៨៩ | បរិញ្ញាបត្រជាន់ខ្ពស់ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ៦ | ហែម ពុទ្ធី | ប | ០១-០៧-១៩៩០ | បរិញ្ញាបត្រជាន់ខ្ពស់ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ៧ | ហាន ប៊ុញ្ញារតនៈ | ប | ០៩-០៧-១៩៩៣ | បរិញ្ញាបត្រជាន់ខ្ពស់ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ៨ | សុខ ហ៊ី | ប | ៣១-០៨-១៩៩៥ | បរិញ្ញាបត្រ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ៩ | ចំ វាសនា | ប | ២៨-០៥-២០០៣ | បរិញ្ញាបត្រ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ១០ | ថាំង ធារ៉ូ | ប | ២២-០៥-២០០៤ | បរិញ្ញាបត្រ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ១១ | ទី រិទ្ធីវិសាល | ប | ១០-១២-២០០០ | បរិញ្ញាបត្រ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ១២ | ហ៊ឹម បញ្ញា | ស | ០៤-០៩-១៩៩១ | បរិញ្ញាបត្រ | អនុមន្ត្រី ថ្នាក់លេខ៤ |
| ១៣ | សុខ អាន | ប | ០៥-០៧-១៩៩៨ | បរិញ្ញាបត្រ | អនុមន្ត្រី ថ្នាក់លេខ៤ |

**មាត្រា២ :** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

នរស. ២៦០៦. ៦៣៩

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសាស្ត្រាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២៦/ ៦៣១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ពិន សុផល** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា២** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ចារ. ២៦០៦. ៦៤០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ឹង ថូរ៉ាក់ស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៩២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការធ្វើអនុប្បយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ :-**

ត្រូវបានធ្វើអនុប្បយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទីតាំងដីមួយកន្លែងដែលមានទំហំ ៣៦ ម៉ែត្រ x ៥៤ ម៉ែត្រ ស្មើនឹង ១ ៩៤៤ ម៉ែត្រការ៉េ នៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល ស្ថិតនៅភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីផ្តល់ជូនសមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា គ្រប់គ្រងជាកម្មសិទ្ធិស្របច្បាប់។

**មាត្រា២ :-**

ត្រូវបានលុបទំហំដីដូចបានកំណត់ក្នុងមាត្រា ១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣ :-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់ប្រើប្រាស់ដោយចីរភាពនិងការធ្វើអនុប្បយោគ លើផ្ទៃដីទំហំ ៣២ហិកតា ៣៤អា( សាមសិបពីរហិកតាសាមសិបបួនអា )ស្ថិតក្នុង ដែនជម្រកសត្វព្រៃភ្នំព្រេចនិងដែនជម្រកសត្វព្រៃកែវសីមា ភូមិសាស្ត្រខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែល ប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការកំណត់និងការបែងចែកតំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំព្រេច ខេត្តមណ្ឌលគិរី
- បានឃើញអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការកំណត់តំបន់សហគមន៍ នៃតំបន់ការពារធម្មជាតិលើផ្ទៃដីទំហំសរុប ៩៣៣ ៥៧៧ ហិកតា
- បានឃើញអនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែប្រែដែនជម្រកសត្វព្រៃភ្នំព្រេច
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែប្រែដែនជម្រកសត្វព្រៃកែវសីមា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាននិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាពមានផ្ទៃដីទំហំ ២ហិកតា ៨៤អា( ពីរហិកតាប៉ែតសិបបួនអា ) ស្ថិតក្នុងដែនជម្រកសត្វព្រៃកែវសីមា ភូមិសាស្ត្រសង្កាត់រមនា ក្រុងសែនមនោរម្យ និងឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១និងនិយាមកា( តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 1984 ) ភ្ជាប់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ត្រូវបានកំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាពមានផ្ទៃដីទំហំ ១ហិកតា ៥អា( មួយហិកតាប្រាំអា ) ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រឃុំពូជ្រៃ ស្រុកពេជ្រាដា និងសង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣និងនិយាមកា( តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 1984 ) ភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

**មាត្រា៣ .-**

ត្រូវបានធ្វើអនុប្បយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋក្រោមលក្ខខណ្ឌជួលក្នុងរយៈពេលមិនលើសពី៥០(ហាសិប)ឆ្នាំលើផ្ទៃដីទំហំ ៣២ហិកតា ៣៤អា(សាមសិបពីរហិកតាសាមសិបបួនអា) ស្ថិតក្នុងភូមិសាស្ត្រឃុំពូជ្រៃ ស្រុកពេជ្រាដា និងសង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥និងនិយាមកា( តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 1984 ) ភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ ដែលផ្ទៃដីនេះបានមកពីការកំណត់ក្នុងមាត្រា១ និងមាត្រា២នៃអនុក្រឹត្យនេះ និងផ្ទៃដីទំហំ ២៨ហិកតា ៤៥អា( ម្ភៃប្រាំបីហិកតាសែសិបប្រាំអា ) ស្ថិតក្នុង

តំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃភ្នំព្រេចនិងតំបន់សហគមន៍នៃដែនជម្រកសត្វព្រៃកែវសីមា ឱ្យក្រុមហ៊ុន គោព្រៃ វីនហ្វាម ឯ.ក សម្រាប់វិនិយោគលើគម្រោងអភិវឌ្ឍន៍អគ្គិសនីដើរដោយថាមពលខ្យល់ អនុភាព១៥០មេហ្គាវ៉ាត់ និងត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធី ដោយក្រសួងបរិស្ថានជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**អ៊ាង សុផល្លែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៤.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការសម្របសម្រួលការងារ របស់ក្រសួង ស្ថាប័ន ជាមួយអង្គការសង្គមស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការសម្របសម្រួលការងាររបស់ក្រសួង ស្ថាប័ន ជាមួយអង្គការសង្គមស៊ីវិល ដែលសរសេរជាអក្សរកាត់ថា **គ.ស.ក.ស.** ដើម្បីពង្រឹងគុណតម្លៃនៃភាពជាដៃគូប្រកបដោយបរិយាបន្ន និងលើកកម្ពស់ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃកិច្ចសហការរវាងក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល សំដៅរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រតាមវិស័យ។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា២ .-**

**គ.ស.ភ.ស.** ជាសេនាធិការជូនរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងតម្រង់ទិសជាយុទ្ធសាស្ត្រ គោលនយោបាយ ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងសកម្មភាពក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល
- ផ្តល់ការគាំទ្រភាពជាអ្នកដឹកនាំនិងកិច្ចសម្របសម្រួលរបស់ក្រសួង ស្ថាប័នជាមួយអង្គការសង្គមស៊ីវិល
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំនិងអនុវត្តផែនការសកម្មភាពសម្រាប់វាយតម្លៃស្ថានភាពកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលតាមវិស័យនីមួយៗ
- ដឹកនាំរៀបចំនិងវាយតម្លៃស្ថានភាពនិងតម្រូវការរបស់ក្រសួង ស្ថាប័នសម្រាប់បំពេញការងារក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល
- ដឹកនាំរៀបចំផែនទីបង្ហាញផ្លូវ រួមទាំងសកម្មភាពជាក់លាក់ សម្រាប់គាំទ្រក្រសួង ស្ថាប័ន ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល
- ដឹកនាំរៀបចំគោលការណ៍ណែនាំស្តីពីកិច្ចសន្ទនាកម្រិតវិស័យជាមួយអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាដៃគូរបស់ក្រសួង ស្ថាប័នជាមួយអង្គការសង្គមស៊ីវិល
- តាមដាននិងវាយតម្លៃសមិទ្ធកម្មនៃភាពជាដៃគូរវាងក្រសួង ស្ថាប័នជាមួយអង្គការសង្គមស៊ីវិល ហើយរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យនិងផ្តល់អនុសាសន៍
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាពរបស់គ.ស.ភ.ស.

**មាត្រា៣ .-**

**គ.ស.ភ.ស.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ឥស្សរជនជាសមាជិករាជរដ្ឋាភិបាល១រូប | ប្រធាន |
| - ប្រធានក្រុមប្រឹក្សាភិបាលវេទិកាសម្ព័ន្ធសង្គមស៊ីវិល | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | អនុប្រធាន |
| - នាយករងខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| - តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |

- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកិច្ចការនារី១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការសហប្រតិបត្តិអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- ប្រធានលេខាធិការដ្ឋាន**គ.ស.ភ.ស.** សមាជិក។

**គ.ស.ភ.ស.** អាចមានសមាសភាពបន្ថែមដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ សមាសភាពជាក់ស្តែងរបស់**គ.ស.ភ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់គ.ស.ភ.ស.

**មាត្រា៤ .-**

**គ.ស.ភ.ស.** ត្រូវប្រជុំរៀងរាល់៦(ប្រាំមួយ)ខែម្តង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធាន**គ.ស.ភ.ស.** អាចកោះប្រជុំវិសាមញ្ញបាន។

ក្នុងករណីប្រធាន**គ.ស.ភ.ស.** អវត្តមានឬមានធុរៈចាំបាច់ ប្រធាន**គ.ស.ភ.ស.** អាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

អនុប្រធាននិងសមាជិក**គ.ស.ភ.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីអវត្តមាន ឬមានធុរៈចាំបាច់ អនុប្រធាននិងសមាជិក**គ.ស.ភ.ស.** នោះ ត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួសក្នុងនាមក្រសួង ស្ថាប័ន ដើម្បីចូលរួមប្រជុំ។

**មាត្រា៥ .-**

ប្រធាន**គ.ស.ភ.ស.** ឬអនុប្រធាន**គ.ស.ភ.ស.** ដែលទទួលសិទ្ធិដឹកនាំកិច្ចប្រជុំ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមកិច្ចប្រជុំ។

**មាត្រា៦ .-**

**គ.ស.ភ.ស.** មានអគ្គលេខាធិការដ្ឋាននៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល ជាលេខាធិការដ្ឋានសម្រាប់បំពេញមុខងាររបស់ខ្លួន។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានវេទិកាសម្ព័ន្ធសង្គមស៊ីវិល ជាប្រធានលេខាធិការដ្ឋាន**គ.ស.ភ.ស.**។

ប្រធានលេខាធិការដ្ឋាន**គ.ស.ភ.ស.** មានសិទ្ធិប្រើមន្ត្រីអគ្គលេខាធិការដ្ឋាននៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ក្នុងករណីចាំបាច់ លេខាធិការដ្ឋាន**គ.ស.ភ.ស.** អាចស្នើសុំមន្ត្រីជាប់កិច្ចសន្យា ឱ្យជួយការងាររបស់ខ្លួនក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី។

តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន**គ.ស.ភ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ភ.ស.**។

**មាត្រា៧ .-**

**គ.ស.ភ.ស.** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការការងារប្រចាំថ្ងៃ។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា៨ .-**

**គ.ស.ភ.ស.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី៦
## រចនាសម្ព័ន្ធតាមក្រសួង ស្ថាប័ន

**មាត្រា៩ .-**

ក្រសួង ស្ថាប័នដែលជាសមាជិក**គ.ស.ភ.ស.** ត្រូវបង្កើតក្រុមការងារដើម្បីដឹកនាំកិច្ចសន្ទនាកម្រិតវិស័យជាមួយអង្គការសង្គមស៊ីវិល។ ការបង្កើតក្រុមការងារនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នរបស់ខ្លួន។

ក្រុមការងារនេះត្រូវប្រើប្រាស់រចនាសម្ព័ន្ធក្រសួង ស្ថាប័នដែលមានស្រាប់ សម្រាប់ផ្តល់ការគាំទ្របច្ចេកទេស។

សមាជិក**គ.ស.ភ.ស.** ដែលត្រូវបានចាត់តាំងពីក្រសួង ស្ថាប័ន ត្រូវធ្វើជាប្រធានក្រុមការងារនេះ។

ក្រុមការងារអាចមានសមាជិកជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ចូលរួមតាមការចាំបាច់។

ក្នុងការរៀបចំតួនាទីនិងភារកិច្ចរបស់ខ្លួន ព្រមទាំងការដឹកនាំកិច្ចសន្ទនា ក្រសួង ស្ថាប័នត្រូវសហការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋាន**គ.ស.ភ.ស.** និងដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នរបស់ខ្លួន។

**មាត្រា១០ .-**

ចំណាយប្រតិបត្តិការសម្រាប់ក្រុមការងាររបស់ក្រសួង ស្ថាប័ន មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នសាមី។

## ជំពូកទី៧
## ប្រព័ន្ធរបាយការណ៍

**មាត្រា១១ .-**

**គ.ស.ភ.ស.** ត្រូវបូកសរុបលទ្ធផលការងាររៀងរាល់៦ខែម្តង ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងផ្តល់អនុសាសន៍ ដោយផ្អែកលើរបាយការណ៍របស់ក្រុមការងារតាមក្រសួង ស្ថាប័ន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២៦
ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលការងាររបស់ក្រសួង ស្ថាប័ន ជាមួយអង្គការសង្គមស៊ីវិល

**អង្គការលេខនៃគណៈកម្មាធិការសម្របសម្រួលការងាររបស់ក្រសួង ស្ថាប័ន ជាមួយអង្គការសង្គមស៊ីវិល**(**គ.ស.ក.ស.**)



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតមូលនិធិកីឡាជនពិការ តេជោសែន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីបរធនបាលកិច្ច
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១២៥/០២២ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៥ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៥/១០៨៣ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ ស្ដីពីការកែសម្រួលព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត**មូលនិធិកីឡាជនពិការ តេជោសែន** ដែលសរសេរជាអក្សរកាត់ថា **ម.ក.ជ.ត.** និងជាភាសាអង់គ្លេស **Techosen Sports For People With Disability Foundation** សរសេរជាអក្សរកាត់ថា **TSPDF** ជាបរធនបាលកិច្ច ដើម្បីគ្រប់គ្រងនិងចាត់ចែងបរធននៃ**ម.ក.ជ.ត.** ក្នុងគោលបំណងគាំទ្រវិស័យកីឡាជនពិការ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើសកម្មភាពទាក់ទងនឹងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ **ម.ក.ជ.ត.**។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **បរធន** សំដៅដល់ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរឱ្យបរធនបាលគ្រប់គ្រងនិងចាត់ចែង សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌកំណត់ដោយអនុក្រឹត្យនេះ
- **បរធនបាល** សំដៅដល់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ក.ជ.ត.**
- **បរធនបាលទាយក** សំដៅដល់បុគ្គលដែលបង្កើតនិងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្តល់ទ្រព្យសម្បត្តិ ឬមូលនិធិដំបូងនៅក្នុងបរធនបាលកិច្ច
- **បរធនបាលកិច្ច** សំដៅដល់កិច្ចការគ្រប់គ្រងនិងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ស្របតាមអនុក្រឹត្យនេះ
- **អត្ថគាហកៈ** សំដៅដល់អត្តពលិកពិការដែលជាអ្នកទទួលផលប្រយោជន៍ពីបរធនបាលកិច្ចនេះ
- **អំណោយ** សំដៅដល់ការផ្ទេរសិទ្ធិកម្មសិទ្ធិឬសិទ្ធិអាស្រ័យផលលើទ្រព្យសម្បត្តិ ដោយស្ម័គ្រចិត្តជូន **ម.ក.ជ.ត.** ដោយគ្មានតម្លៃតបស្នងឬកាតព្វកិច្ចត្រឡប់។

## ជំពូកទី២
## អត្តសញ្ញាណ ប្រភពធនធាន និងបរធនបាលកិច្ច
## នៃម.ក.ជ.ត.

**មាត្រា៤ .-**

**ម.ក.ជ.ត.** ជាបរធនបាលកិច្ច ដែលបង្កើតឡើងដើម្បីស្វែងរកអំណោយមនុស្សធម៌ មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ សាសនា និន្នាការនយោបាយ និងបម្រើឱ្យផលប្រយោជន៍កីឡាជនពិការ។

**ម.ក.ជ.ត.** មានប្រភពបរធនដូចតទៅ៖

- អំណោយរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលនិងឥស្សរជន
- អំណោយឧបត្ថម្ភផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជា
- អំណោយ ឧបត្ថម្ភជន និងវិភាគទាន
- អំណោយរបស់សប្បុរសជន ដៃគូអភិវឌ្ឍ និងវិស័យឯកជន
- អំណោយរបស់សមាជិកគាំទ្រ
- ប្រភពស្របច្បាប់ផ្សេងៗទៀត។

**មាត្រា៥ .-**

បរធនបាលទាយករបស់**ម.ភ.ជ.ត.** គឺរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**ម.ភ.ជ.ត.** មានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** និងឯកឧត្តម **ហ៊ុន ម៉ានី** អនុប្រធានគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា ជាស្ថាបនិក។

**មាត្រា៦ .-**

**ម.ភ.ជ.ត.** មានរូបសញ្ញានិងត្រាក្នុងការបំពេញភារកិច្ចរបស់ខ្លួន តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល **ម.ភ.ជ.ត.**។

**ម.ភ.ជ.ត.** មានទីស្នាក់ការកណ្តាលនៅក្នុងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា។

## ជំពូកទី៣
## សមាជិកភាពនៃម.ភ.ជ.ត.

**មាត្រា៧ .-**

**ម.ភ.ជ.ត.** មានសមាជិកតាមការចាំបាច់។ ការសម្រេចបញ្ចូលសមាជិកភាព ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** ផ្អែកតាមលក្ខណសម្បត្តិនៃបុគ្គលនីមួយៗ។

**មាត្រា៨ .-**

សមាជិក**ម.ភ.ជ.ត.** មាន៣(បី)ប្រភេទគឺៈ

- សមាជិកស្ថាបនិក
- សមាជិកកិត្តិយស
- សមាជិកឧបត្ថម្ភគាំទ្រ។

ផ្អែកតាមការស្នើសុំរបស់សាមីជន សមាជិកកិត្តិយស និងសមាជិកឧបត្ថម្ភគាំទ្រ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់អាចត្រូវបានជ្រើសរើសជាបេក្ខភាពតំណាងអគ្គពលិកពិការក្នុងក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.**។

បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការទទួលស្គាល់និងការបញ្ចប់សមាជិកភាព ព្រមទាំងគុណវុឌ្ឍិសម្រាប់ការជ្រើសរើសជាបេក្ខភាពតំណាងអគ្គពលិកពិការក្នុងក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.**។

## ជំពូកទី៤
## សមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសិទ្ធិ
## របស់ក្រុមប្រឹក្សាបរធនបាលម.ភ.ជ.ត.

**មាត្រា៩ .-**

ក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** មានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១- ឥស្សរជនជាន់ខ្ពស់១រូប | ប្រធាន |
| ២- អគ្គលេខាធិការនៃគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |

៤- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី១រូប អនុប្រធាន
៥- តំណាងក្រសួងអប់រំ យុវជន និងកីឡា១រូប អនុប្រធាន
៦- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប អនុប្រធាន
៧- តំណាងកាកបាទក្រហមកម្ពុជា១រូប អនុប្រធាន
៨- តំណាងក្រសួងមហាផ្ទៃ១រូប សមាជិក
៩- តំណាងក្រសួងការពារជាតិ១រូប សមាជិក
១០- តំណាងក្រសួងព័ត៌មាន១រូប សមាជិក
១១- តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប សមាជិក
១២- តំណាងក្រសួងទេសចរណ៍១រូប សមាជិក
១៣- តំណាងសភាពាណិជ្ជកម្មកម្ពុជា១រូប សមាជិក
១៤- អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា១រូប សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្ដែងរបស់ក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ឥ.** ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល សម្រាប់អាណត្តិ៣ឆ្នាំ និងអាចបន្តទៀតបានតាមការស្នើសុំរបស់ក្រសួង ស្ថាប័ន ដែលសមាជិកនោះជាតំណាង។

**មាត្រា១០ .-**

ក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ឥ.** មានតួនាទី ភារកិច្ច និងសិទ្ធិ ដូចខាងក្រោម៖

- ពិនិត្យនិងអនុម័តថវិកាប្រចាំឆ្នាំនិងរបាយការណ៍ហិរញ្ញវត្ថុរបស់**ម.ភ.ជ.ឥ.**
- តាមដានត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃវឌ្ឍនភាពនៃកិច្ចដំណើរការរបស់**ម.ភ.ជ.ឥ.**
- អំពាវនាវ កៀរគរធនធានហិរញ្ញវត្ថុនិងសម្ភារៈនានា ជាសាធារណៈ ពីប្រភពនានាទាំងក្នុងនិងក្រៅប្រទេស ដើម្បីបម្រើដល់គោលបំណងនិងគោលដៅដូចមានចែងក្នុងអនុក្រឹត្យនេះ
- ពិនិត្យនិងរៀបចំគោលនយោបាយនិងនីតិវិធីផ្ដល់ការឧបត្ថម្ភ ដើម្បីទ្រទ្រង់**ម.ភ.ជ.ឥ.**
- គ្រប់គ្រងនិងប្រើប្រាស់ថវិកាដែលទទួលបានពីអំណោយ ឧបត្ថម្ភធន ឬវិភាគទាន ឱ្យមានតម្លាភាព ប្រសិទ្ធភាព និងសក្ដិសិទ្ធិភាព ដើម្បីទទួលបាននូវជំនឿទុកចិត្តពីសាធារណជន
- ចាត់ចែងនិងគ្រប់គ្រងការវិនិយោគរបស់**ម.ភ.ជ.ឥ.** តាមច្បាប់ជាធរមាន
- សហការជាមួយស្ថាប័នឬមូលនិធិនានា ដើម្បីការរីកចម្រើនប្រកបដោយចីរភាពនៃ**ម.ភ.ជ.ឥ.**
- ដាក់ចេញនូវបែបបទនិងនីតិវិធីពាក់ព័ន្ធនឹងការគ្រប់គ្រងនិងកិច្ចដំណើរការនៃ**ម.ភ.ជ.ឥ.**
- បង្កើតគណៈកម្មការជំនាញឬក្រុមការងារតាមការចាំបាច់ ដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព។

**មាត្រា១១ .-**

ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ឥ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់**ម.ភ.ជ.ឥ.**។ បទបញ្ជាផ្ទៃក្នុងរបស់**ម.ភ.ជ.ឥ.** ត្រូវដាក់ឱ្យអនុវត្តដោយសេចក្ដីសម្រេចរបស់ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ឥ.**។

**មាត្រា១២ .-**

ក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ឥ.** ត្រូវប្រជុំការងារយ៉ាងតិច១ដងក្នុងមួយឆ្នាំ ឬអាចប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ឥ.**។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ឥ.** អាចប្រគល់សិទ្ធិឱ្យអនុប្រធានណាម្នាក់ដឹកនាំកិច្ចប្រជុំជំនួស។

កិច្ចប្រជុំក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកយ៉ាងតិចពីរភាគបី។

ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ននានា អង្គការ សមាគមជាតិ អន្តរជាតិ ក្រុមហ៊ុនឯកជន ម្ចាស់ជំនួយ ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** និងឥស្សរជននានា ដែលមានបទពិសោធលើវិស័យកីឡា វិស័យពិការភាព និងវិស័យនានា ឱ្យចូលរួមប្រជុំបាន តែតំណាងទាំងនោះពុំមានសិទ្ធិបោះឆ្នោតឡើយ។

**មាត្រា១៣ .–**

រាល់ការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** អាចទុកជាបានការ លុះត្រាតែមានសំឡេងគាំទ្រភាគច្រើននៃសមាជិកមានវត្តមាន។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាបរធនបាល **ម.ភ.ជ.ត.** មានឧត្តមានុភាព។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយតម្កល់ទុកនៅទីស្នាក់ការកណ្ដាលរបស់**ម.ភ.ជ.ត.** និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ។

## ជំពូកទី៥
## អង្គភាពប្រតិបត្តិនៃម.ភ.ជ.ត.

**មាត្រា១៤ .–**

**ម.ភ.ជ.ត.** មានអង្គភាពប្រតិបត្តិ ដែលប្រើប្រាស់ធនធាននៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា សម្រាប់អនុវត្តកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់**ម.ភ.ជ.ត.**។

**មាត្រា១៥ .–**

**ម.ភ.ជ.ត.** មានអង្គភាពប្រតិបត្តិមួយ សម្រាប់អនុវត្តកិច្ចការប្រចាំថ្ងៃរបស់**ម.ភ.ជ.ត.**។

អង្គភាពប្រតិបត្តិនៃ**ម.ភ.ជ.ត.** មានតួនាទីដឹកនាំនិងគ្រប់គ្រងការអនុវត្តផែនការសកម្មភាពដែលបានអនុម័តដោយក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.**។

អង្គភាពប្រតិបត្តិនៃ**ម.ភ.ជ.ត.** ត្រូវគ្រប់គ្រងដោយនាយកប្រតិបត្តិ១រូប ដែលជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងមាននាយករងមួយចំនួនជាជំនួយការ ដែលជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា។

នាយកប្រតិបត្តិ ត្រូវបានតែងតាំងនិងបញ្ចប់តំណែងទៅតាមអាណត្តិ ជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា។ នាយករង ត្រូវបានតែងតាំងនិងបញ្ចប់តំណែងដោយសេចក្ដីសម្រេចរបស់ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.**។

អង្គភាពប្រតិបត្តិនៃ**ម.ភ.ជ.ត.** មានការិយាល័យមួយចំនួនដែលអាចដំណើរការគ្រប់គ្រងការងារប្រចាំថ្ងៃ និងមានបុគ្គលិកជាមន្ត្រីមកពីគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា មន្ត្រីបច្ចេកទេសជាប់កិច្ចសន្យា និងអ្នកស្ម័គ្រចិត្តតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់នាយកប្រតិបត្តិ។

អង្គភាពប្រតិបត្តិនៃ**ម.ភ.ជ.ត.** មានសិទ្ធិជ្រើសរើសទីប្រឹក្សាឬជំនួយការ ដើម្បីជួយបំពេញការងារតាមការចាំបាច់។ ទីប្រឹក្សាឬជំនួយការ ត្រូវបានតែងតាំងដោយសេចក្ដីសម្រេចរបស់ប្រធានក្រុមប្រឹក្សាបរធនបាល **ម.ភ.ជ.ត.**។

**មាត្រា១៦ .-**

អង្គភាពប្រតិបត្តិនៃ**ម.ភ.ជ.ត.** មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការសកម្មភាព គោលការណ៍ និងបទប្បញ្ញត្តិដើម្បីសុំការអនុម័តពីក្រុមប្រឹក្សាបរធនបាល **ម.ភ.ជ.ត.**
- អនុវត្តផែនការសកម្មភាព គោលការណ៍ និងបទប្បញ្ញត្តិដែលបានអនុម័តដោយក្រុមប្រឹក្សាបរធនបាល **ម.ភ.ជ.ត.**
- កាន់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ក្រុមប្រឹក្សាបរធនបាល **ម.ភ.ជ.ត.**
- សម្របសម្រួលជាមួយស្ថាប័ននិងអ្នកពាក់ព័ន្ធ ដើម្បីអនុវត្តការផ្សព្វផ្សាយអំពី**ម.ភ.ជ.ត.**
- សហការនិងទំនាក់ទំនងធ្វើលិខិតអំពាវនាវ ដើម្បីស្នើសុំការឧបត្ថម្ភ
- រៀបចំមធ្យោបាយប្រមូលមូលនិធិពីសប្បុរសជននៅតាមទីតាំងក្នុងនិងក្រៅប្រទេស
- រៀបចំកម្មវិធីផ្សេងៗតាមការចាំបាច់ សំដៅកៀរគរវិភាគទានពីសប្បុរសជន
- បំពេញមុខងាររដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេស ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.**។

## ជំពូកទី៦

## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ម.ភ.ជ.ត.

**មាត្រា១៧ .-**

ធនធានហិរញ្ញវត្ថុនៃ**ម.ភ.ជ.ត.** ត្រូវរក្សាទុកនៅក្នុងគណនីរបស់ធនាគារណាមួយ តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** នៅក្រោមឈ្មោះផ្ទាល់របស់គណនី**ម.ភ.ជ.ត.**។

**មាត្រា១៨ .-**

ចំណូលនិងចំណាយសម្រាប់ដំណើរការ**ម.ភ.ជ.ត.** ត្រូវគ្រោងក្នុងផែនការថវិកាប្រចាំឆ្នាំនៃ**ម.ភ.ជ.ត.**។

ការទូទាត់និងការបើកប្រាក់ ដូចមានកំណត់ក្នុងនីតិវិធីនិងបទបញ្ជាផ្ទៃក្នុងនៃ**ម.ភ.ជ.ត.** អាចត្រូវបានផ្ដល់សិទ្ធិឱ្យនាយកប្រតិបត្តិនៃអង្គភាពប្រតិបត្តិនៃ**ម.ភ.ជ.ត.** តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ភ.ជ.ត.**។

**មាត្រា១៩ .-**

អង្គភាពប្រតិបត្តិនៃ**ម.ភ.ជ.ត.** ចាំបាច់ត្រូវកត់ត្រារាល់ចំណូល ចំណាយ រក្សាទុកនូវរាល់ឯកសារពាក់ព័ន្ធ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមប្រព័ន្ធស្ដង់ដាគណនេយ្យកម្ពុជា ដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាលនៃ**ម.ភ.ជ.ត.** ពិនិត្យនិងសម្រេច។

**មាត្រា២០ .-**

នាយកប្រតិបត្តិនៃ**ម.ភ.ជ.ត.** ត្រូវផ្ដល់របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.**។ ប្រធានក្រុមប្រឹក្សាបរធនបាល**ម.ភ.ជ.ត.** ត្រូវផ្ដល់របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ជូនបរធនបាលទាយក។

## ជំពូកទី៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា២១ .-**

ការគ្រប់គ្រងនិងប្រើប្រាស់ថវិការបស់**ម.ភ.ជ.ត.** ជាកម្មវត្ថុនៃការធ្វើសវនកម្មដោយសវនករឯករាជ្យ។

**មាត្រា២២ .-**

ប្រធានក្រុមប្រឹក្សាភិបាល**ម.ភ.ជ.ត.** ត្រូវចេញសេចក្តីសម្រេចស្តីពីនីតិវិធីអនុវត្តថវិកាលម្អិតបន្ថែមតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិការបស់**ម.ភ.ជ.ត.**។

**មាត្រា២៣ .-**

ក្រុមប្រឹក្សាភិបាល**ម.ភ.ជ.ត.** ត្រូវដាក់ចេញនូវគោលនយោបាយវិនិយោគហិរញ្ញវត្ថុដែលផ្តោតលើសុវត្ថិភាពទុននិងនិរន្តរភាពថវិកា ដោយចៀសវាងការវិនិយោគដែលមានហានិភ័យខ្ពស់ និងបង្កើនសកម្មភាពសេដ្ឋកិច្ចបែបសង្គម ដើម្បីធានាថាលំហូរថវិកាមានស្ថិរភាព សម្រាប់គាំទ្រអត្ថពលិកពិការក្នុងរយៈពេលវែង។

**មាត្រា២៤ .-**

**ម.ភ.ជ.ត.** ត្រូវបង្កើតយន្តការតាមដាននិងវាយតម្លៃផលប៉ះពាល់សង្គមជាប្រចាំ ដើម្បីវាស់វែងនូវប្រសិទ្ធភាពជំនួយនិងវឌ្ឍនភាពនៃសមត្ថភាព ជីវភាព សុខភាពផ្លូវកាយផ្លូវចិត្ត និងសិទ្ធិរបស់ជនពិការក្នុងសង្គម។ របាយការណ៍ផលប៉ះពាល់សង្គមនេះ ត្រូវបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ ដើម្បីបង្ហាញអំពីតម្លាភាពនិងគណនេយ្យភាពចំពោះសប្បុរសជននិងរាជរដ្ឋាភិបាល។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៩៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សេវាអត្តសញ្ញាណកម្ម ដែលមិនតម្រូវឱ្យបង់កម្រៃសេវា និងតម្រូវឱ្យបង់កម្រៃសេវា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩២៥/០៣០ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៦៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលមាត្រា៨ និងមាត្រា១០ នៃអនុក្រឹត្យលេខ៦៨អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៥២ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ ស្តីពីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ ស្តីពីសមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ប្រភេទសេវាអត្តសញ្ញាណកម្មដែលមិនតម្រូវឱ្យបង់កម្រៃសេវា និងតម្រូវឱ្យបង់កម្រៃសេវា ដើម្បីធានាដល់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងការប្រមូលចំណូលមិនមែនសារពើពន្ធ សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ ព្រមទាំងជួយសម្រួលបន្ទុកចំណាយរបស់ប្រជាពលរដ្ឋ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។



ស

មាត្រា៣.-

ទិន្នន័យអត្តសញ្ញាណបុគ្គល ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ គឺជាទិន្នន័យ និងប្រភពទិន្នន័យផ្លូវការតែមួយគត់ដែលអាចប្រើប្រាស់បានសម្រាប់ការផ្តល់សេវាសាធារណៈ ស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី២

## ប្រភេទសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដែលមិនតម្រូវឱ្យបង់កម្រៃសេវា

មាត្រា៤.-

ប្រភេទសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដែលមិនតម្រូវឱ្យបង់កម្រៃសេវា រួមមាន៖

ក- សេវាអត្រានុកូលដ្ឋាន

១- ការចុះបញ្ជី និងផ្តល់សំបុត្រកំណើត ឬសំបុត្រមរណភាព ឬសំបុត្រអាពាហ៍ពិពាហ៍ដំបូង។

២- ការកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន ដែលជាកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋាន។

៣- ការចុះបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ។

ខ- សេវាស្ថិតិប្រជាពលរដ្ឋ និងគ្រប់គ្រងការស្នាក់នៅ

១- ការផ្តល់សៀវភៅស្នាក់នៅដំបូង។

២- ការកែតម្រូវទិន្នន័យក្នុងសៀវភៅស្នាក់នៅ ដែលជាកំហុសបច្ចេកទេសដោយមន្ត្រីចុះបញ្ជី។

៣- ការបន្ថែម ឬបន្ថយសមាជិក ក្នុងសៀវភៅស្នាក់នៅ។

៤- ការផ្តល់សៀវភៅគ្រួសារដំបូង។

៥- ការកែតម្រូវទិន្នន័យក្នុងសៀវភៅគ្រួសារ ដែលជាកំហុសបច្ចេកទេសដោយមន្ត្រីចុះបញ្ជី។

៦- ការបន្ថែម ឬបន្ថយសមាជិកគ្រួសារ ក្នុងសៀវភៅគ្រួសារ។

គ- សេវាអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

១- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង។

២- ការកែតម្រូវទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលជាកំហុសបច្ចេកទេសដោយមន្ត្រីចុះបញ្ជី។

ឃ- ការផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល និងបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ក្នុងវិស័យយុត្តិធម៌ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដែលស្នើសុំដោយអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ។

## ជំពូកទី៣

## ប្រភេទសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដែលតម្រូវឱ្យបង់កម្រៃសេវា

មាត្រា៥.-

ប្រភេទសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ដែលតម្រូវឱ្យបង់កម្រៃសេវា រួមមាន៖

ក- សេវាអត្រានុកូលដ្ឋាន

១- ការផ្តល់សំបុត្រកំណើត ឬសំបុត្រមរណភាព ឬសំបុត្រអាពាហ៍ពិពាហ៍ ច្បាប់ដើមឡើងវិញ ករណីខូចខាត ឬបាត់បង់។

២- ការផ្តល់បណ្ណប្រកាសអាពាហ៍ពិពាហ៍។
៣- ការផ្តល់សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្រមរណភាព ឬសំបុត្រអាពាហ៍ពិពាហ៍។
៤- ការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានឱ្យមានសង្គតិភាពទិន្នន័យ ករណីមានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។
៥- ការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចតុលាការ។
៦- ការផ្តល់សម្រង់បញ្ជីកំណើតរស់ ឬមរណភាព ឬអាពាហ៍ពិពាហ៍។
៧- ការផ្តល់សេចក្តីចម្លងសំបុត្រកំណើត សម្រាប់បុគ្គលដែលបានទទួលព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ។
៨- ការផ្តល់សេចក្តីសម្រេចស្តីពីការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋខ្មែរ និងជនបរទេស។
៩- ការផ្តល់លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ។
១០- ការផ្តល់លិខិតបញ្ជាក់ការលែងលះតាមសេចក្តីសម្រេចរបស់តុលាការ។

ខ- សេវាស្ថិតិប្រជាពលរដ្ឋ និងគ្រប់គ្រងការស្នាក់នៅ
១- ការផ្តល់សៀវភៅស្នាក់នៅទុតិយតា ករណីខូចខាត ឬបាត់បង់។
២- ការកែតម្រូវទិន្នន័យក្នុងសៀវភៅស្នាក់នៅឱ្យមានសង្គតិភាពទិន្នន័យ ករណីមានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។
៣- ការផ្តល់លិខិតបញ្ជាក់ទីលំនៅសម្រាប់ពលរដ្ឋខ្មែរ។
៤- ការផ្តល់លិខិតបញ្ជាក់ទីលំនៅសម្រាប់ជនបរទេស។
៥- ការផ្តល់សៀវភៅគ្រួសារទុតិយតា ករណីខូចខាត ឬបាត់បង់។
៦- ការកែតម្រូវទិន្នន័យក្នុងសៀវភៅគ្រួសារ ឱ្យមានសង្គតិភាពទិន្នន័យ ករណីមានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។
៧- ការស្នើសុំផ្លាស់ប្តូរទីលំនៅ។

គ- សេវាអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
១- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ដោយសេវាឆាប់រហ័ស។
២- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ករណីអស់សុពលភាពដោយសេវាឆាប់រហ័ស។
៣- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ករណីខូចខាត ឬបាត់បង់។
៤- ការកែតម្រូវទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឱ្យមានសង្គតិភាពទិន្នន័យ ករណីមានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។
៥- ការប្តូររូបថត និង/ឬអាសយដ្ឋានលើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មុនអស់សុពលភាព ឬសម្រាប់ព្រះសង្ឃដែលលាចាកសិក្ខាបទ។

ឃ- សេវាលិខិតឆ្លងដែន
១- ការផ្តល់លិខិតឆ្លងដែន។
២- ការផ្តល់លិខិតឆ្លងដែនបណ្តោះអាសន្ន។
៣- ការផ្តល់លិខិតធ្វើដំណើរសម្រាប់ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស។

៤- សេវាថតរូប និងរៀបចំសំណុំឯកសារធ្វើលិខិតឆ្លងដែន លិខិតឆ្លងដែនបណ្តោះអាសន្ន ឬ លិខិតធ្វើដំណើរសម្រាប់ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស។

៥- ការផ្តល់លេខពិសេសលិខិតឆ្លងដែន។

ង- សេវាសញ្ជាតិ

១- ការរៀបចំបែបបទស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម។

២- ការរៀបចំបែបបទស្នើសុំលះបង់សញ្ជាតិខ្មែរ។

៣- ការរៀបចំបែបបទស្នើសុំទាមទារសញ្ជាតិខ្មែរ តាមរយៈអាពាហ៍ពិពាហ៍។

៤- ការរៀបចំបែបបទការងារសម្បថ បន្ទាប់ពីទទួលបានព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ។

ច- សេវាផ្ទៀងផ្ទាត់ទិន្នន័យ សេវាបញ្ជាក់អត្តសញ្ញាណបុគ្គល និងសេវាប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល លើការងារអត្តសញ្ញាណកម្ម

១- ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល។

២- ការផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល។

៣- ការផ្តល់លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល។

៤- ការផ្តល់សេវាភ្ជាប់ប្រព័ន្ធផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គលប្រចាំឆ្នាំ។

៥- សេវាប្រើប្រាស់ និងថែទាំគណនីលើកម្មវិធី **អត្តសញ្ញាណកម្មខ្មែរអេឡិចត្រូនិក** (Khmer eID)។

៦- សេវាប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រអត្តសញ្ញាណឌីជីថល។

**មាត្រា៦.-**

ទម្រង់ បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់សេវាសាធារណៈអត្តសញ្ញាណកម្ម និងការប្រមូលចំណូលទៅតាមប្រភេទសេវានីមួយៗ ត្រូវអនុវត្តតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ការបង់កម្រៃសេវាសាធារណៈលើការងារអត្តសញ្ញាណកម្ម ត្រូវអនុវត្តតាមតម្លៃសេវាសាធារណៈដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៧.-**

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង់កម្រៃសេវាសាធារណៈលើការងារអត្តសញ្ញាណកម្មដែលនៅជាធរមាន ត្រូវបន្តអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួស។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៤កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន សម្តេចមហាបវរធិបតី
នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ទិវាជាតិប្រជាជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់យកថ្ងៃទី១១ ខែកក្កដា រៀងរាល់ឆ្នាំ ជា **ទិវាជាតិប្រជាជន** ក្នុងគោលបំណងរំឭកដល់ជនរួមជាតិទាំងអស់ឱ្យបន្តផ្តោតការយកចិត្តទុកដាក់និងរួមគ្នាដោះស្រាយបញ្ហាបម្រែបម្រួលប្រជាសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីកសាងសង្គមជាតិមួយប្រកបដោយភាពធន់ប្រជាជននិងប្រកបដោយសុខដុមរមនា។



៥

**មាត្រា២ .-**

គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស វិស័យឯកជន និងគ្រឹះស្ថានសិក្សានានា ចូលរួមបំផុសដល់សាធារណជនដើម្បីយកចិត្តទុកដាក់និងរួមគ្នាដោះស្រាយបញ្ហាបម្រែបម្រួលប្រជាសាស្ត្រ។

ក្រសួងផែនការ ត្រូវរៀបចំទិវាជាតិប្រជាជន ដោយសហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស វិស័យឯកជន និងគ្រឹះស្ថានសិក្សានានា ព្រមទាំងភាគីពាក់ព័ន្ធ។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រឈៃ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ៖១០០ អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន**

**នៃគណៈកម្មការជាតិយូណេស្កូកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៤/៩៥៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មការជាតិយូណេស្កូកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិយូណេស្កូកម្ពុជា(**គ.ជ.យ.ក.**)។

## ជំពូកទី២

## ភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន គ.ជ.យ.ក.

**មាត្រា២ .-**

អគ្គលេខាធិការដ្ឋាន **គ.ជ.យ.ក.** មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងគាំទ្រដល់ការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានារបស់ **គ.ជ.យ.ក.**
- សហការនិងសម្របសម្រួលការងារជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងបុគ្គលនានាក្នុងការតាមដានការអនុវត្តនូវរាល់សន្ធិសញ្ញា អនុសញ្ញា និងគោលការណ៍ប្រតិបត្តិនានាក្នុងក្របខ័ណ្ឌអង្គការយូណេស្កូ
- សម្របសម្រួលនិងសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការស្រាវជ្រាវ និងរៀបចំចងក្រងឯកសារបេតិកភណ្ឌវប្បធម៌រូបី អរូបី បេតិកភណ្ឌឯកសារ ដើម្បីបន្តនីតិវិធីចុះក្នុងបញ្ជីនានារបស់អង្គការយូណេស្កូ
- សម្របសម្រួលនិងសហការជាមួយអង្គភាពក្នុងក្រសួង ក្នុងការរៀបចំផែនការសកម្មភាពដែលពាក់ព័ន្ធនឹងការអភិរក្សបេតិកភណ្ឌធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ជាតិ ទាំងរូបីនិងអរូបី បេតិកភណ្ឌឯកសារដែលបានចុះបញ្ជីជាស្ថាពរតាមនីតិវិធីរបស់អង្គការយូណេស្កូ
- លើកសំណើបង្កើតយន្តការចាំបាច់សម្រាប់កិច្ចការតាមវិស័យដែលពាក់ព័ន្ធនឹងតួនាទី ភារកិច្ចរបស់ **គ.ជ.យ.ក.** និងផ្តល់ការគាំទ្រអនុវត្តដល់សកម្មភាពនានាជាប្រចាំរបស់យន្តការនេះ
- សម្របសម្រួល គ្រប់គ្រងការងាររដ្ឋបាល និងបច្ចេកទេសដើម្បីធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់ **គ.ជ.យ.ក.**
- សម្របសម្រួល និងអនុវត្តការងារប្រចាំថ្ងៃតាមការណែនាំនិងសេចក្តីសម្រេចនានារបស់ **គ.ជ.យ.ក.**
- ពិនិត្យតាមដាន និងសម្របសម្រួលផ្តល់របាយការណ៍ទាក់ទងនឹងការអនុវត្តអនុសញ្ញា ពិធីសារ អនុសាសន៍ និងកម្មវិធីនានារបស់អង្គការយូណេស្កូ

- សម្របសម្រួល និងគាំទ្រដល់ការពង្រឹងទំនាក់ទំនងជាមួយនឹងគណៈកម្មការជាតិយូណេស្កូនៃបណ្តារដ្ឋភាគីផ្សេងទៀត ជាពិសេសជាមួយនឹងគណៈកម្មការជាតិយូណេស្កូនៅក្នុងតំបន់ តាមរយៈការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទូទៅ ការផ្លាស់ប្តូរបទពិសោធន៍ ការបង្កើតនិងការអនុវត្តកម្មវិធីរួមគ្នាដើម្បីជាប្រយោជន៍ដល់កម្ពុជាក្នុងវិស័យពាក់ព័ន្ធនឹងអង្គការយូណេស្កូ
- សម្របសម្រួល សហការជ្រើសរើស និងបញ្ជូនគម្រោងអាទិភាពទាំងឡាយដែលរៀបចំដោយក្រសួង ស្ថាប័ន និងបុគ្គលក្នុងការចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល អាហារូបករណ៍ ពានរង្វាន់ និងកម្មវិធីផ្សេងៗក្នុងក្របខ័ណ្ឌរបស់អង្គការយូណេស្កូ
- រាយការណ៍អំពីការគាំទ្រនិងការបោះឆ្នោតជ្រើសរើសបេក្ខភាពជាសមាជិកនានាក្នុងតំណែងរបស់អង្គការយូណេស្កូ
- ចូលរួមអនុវត្តគម្រោងដែលទទួលបានមូលនិធិពីអង្គការយូណេស្កូឬដៃគូសហការអន្តរជាតិផ្សេងៗដើម្បីលើកស្ទួយវិស័យអប់រំ វប្បធម៌ វិទ្យាសាស្ត្រ ទេសចរណ៍ និងព័ត៌មាន
- សម្របសម្រួលនិងសហការរៀបចំឯកសារនានាដើម្បីចូលរួមតំណាងរាជរដ្ឋាភិបាល ក្នុងមហាសន្និបាតសន្និសីទទូទៅ កិច្ចប្រជុំអន្តររដ្ឋាភិបាល សិក្ខាសាលា និងកម្មវិធីនានា ដែលរៀបចំដោយអង្គការយូណេស្កូ
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងធនធានមនុស្សក្នុងបុព្វហេតុនៃការកសាងអភិវឌ្ឍនិងលើកស្ទួយវិស័យពាក់ព័ន្ធនឹងអង្គការយូណេស្កូ
- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិកា គម្រោងថវិកាប្រចាំឆ្នាំ និងឯកសារពាក់ព័ន្ធថវិកានានាសម្រាប់គាំទ្រដំណើរការការងាររបស់ **គ.ជ.យ.ក.** និងរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.យ.ក.**
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារ និងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាពការងាររបស់ **គ.ជ.យ.ក.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.ជ.យ.ក.**។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គ.ជ.យ.ក.

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាន **គ.ជ.យ.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរង **គ.ជ.យ.ក.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

**មាត្រា៤ .-**

អគ្គលេខាធិការត្រូវធ្វើការបែងចែកភារកិច្ច ដល់អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន **គ.ជ.យ.ក.**។

**មាត្រា៥ .-**

អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន **គ.ជ.យ.ក.** ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះ **គ.ជ.យ.ក.**។

**មាត្រា៦ .-**

អគ្គលេខាធិការដ្ឋាន **គ.ជ.យ.ក.** ប្រើប្រាស់មន្ត្រីរាជការ មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីផ្សេងទៀតរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

អគ្គលេខាធិការដ្ឋាន **គ.ជ.យ.ក.** អាចមានក្រុមការងារជំនាញតាមការចាំបាច់ ដើម្បីជួយគាំទ្រដល់ដំណើរការនៃការអនុវត្តភារកិច្ចរបស់ខ្លួន ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធាន **គ.ជ.យ.ក.**។

## ជំពូកទី៤
## ប្រភពធនធានរបស់អគ្គលេខាធិការដ្ឋាន គ.ជ.យ.ក.

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាន **គ.ជ.យ.ក.** មានប្រភពធនធានសម្រាប់អនុវត្តសកម្មភាពដោយថវិកាជាតិនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងប្រភពធនធានស្របច្បាប់ផ្សេងទៀត។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨៩២ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយការងារ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីនគរបាលជាតិ ចំនួន ៩២រូប នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | ឡុង មិថុនា | អត្តលេខ ៧៧៨៥៧ | អនុប្រធាននាយកដ្ឋាន |
| ២-ឧត្តមសេនីយ៍ត្រី | លី សារ័ន្ត | អត្តលេខ ៥៥៣៩៥ | អនុប្រធាននាយកដ្ឋាន |
| ៣-ឧត្តមសេនីយ៍ត្រី | ឃឹន រ៉ាវី | អត្តលេខ ៦៤៣១៤ | អនុប្រធាននាយកដ្ឋាន |

| | | | |
|---|---|---|---|
| ៤-វរសេនីយ៍ឯក | ឡុង កត់ | អត្តលេខ ៣៧៧១៦ | អនុប្រធាននាយកដ្ឋាន |
| ៥-វរសេនីយ៍ឯក | វ៉េក មុន្នីស័ក្ត | អត្តលេខ ៥៦១៨៤ | អនុប្រធាននាយកដ្ឋាន |
| ៦-វរសេនីយ៍ឯក | ធន់ វុទ្ធី | អត្តលេខ ៦៨១៨៩ | អនុប្រធាននាយកដ្ឋាន |
| ៧-វរសេនីយ៍ឯក | សូ រតនៈ | អត្តលេខ ៩០៧៧២ | អនុប្រធាននាយកដ្ឋាន |
| ៨-វរសេនីយ៍ទោ | ពុំ មន្នីរ័ត្ន | អត្តលេខ ៧៤៨៧៦ | អនុប្រធាននាយកដ្ឋាន |
| ៩-វរសេនីយ៍ទោ | សេង ឆេង | អត្តលេខ ៩៣៣៦៥ | អនុប្រធាននាយកដ្ឋាន |
| ១០-វរសេនីយ៍ទោ | សុខ ចរិយា | អត្តលេខ ៧៧៨១៥ | នាយការិយាល័យ |
| ១១-វរសេនីយ៍ឯក | អ៊ុំ វិបុល | អត្តលេខ ៣៧៣៩៦ | នាយរងការិយាល័យ |
| ១២-វរសេនីយ៍ឯក | យឹម ថាន់នី | អត្តលេខ ៦៥២៦៩ | នាយរងការិយាល័យ |
| ១៣-វរសេនីយ៍ទោ | អ៊ឹង ស្រស់ | អត្តលេខ ៣០៣៩៨ | នាយរងការិយាល័យ |
| ១៤-វរសេនីយ៍ទោ | យ៉េង សំណាង | អត្តលេខ ៧៣៩៨៦ | នាយរងការិយាល័យ |
| ១៥-វរសេនីយ៍ទោ | ប៉េង ចំណាប់ | អត្តលេខ ៧៤៧៩៨ | នាយរងការិយាល័យ |
| ១៦-វរសេនីយ៍ទោ | សួន ស្រីរតនៈ | អត្តលេខ ៧៥២២១ | នាយរងការិយាល័យ |
| ១៧-វរសេនីយ៍ទោ | ង៉ឹង គីមសេង | អត្តលេខ ៧៧៨២៦ | នាយរងការិយាល័យ |
| ១៨-វរសេនីយ៍ទោ | ស្រី សុវត្ថា | អត្តលេខ ៩០៧៧៦ | នាយរងការិយាល័យ |
| ១៩-វរសេនីយ៍ឯក | យឹម វិបុល | អត្តលេខ ៥៤៤៣១ | នាយរងប៉ុស្តិ៍ |
| ២០-វរសេនីយ៍ឯក | ប្រាក់ ពេញ | អត្តលេខ ៧២០៥៥ | នាយរងប៉ុស្តិ៍ |
| ២១-វរសេនីយ៍ទោ | តាក វណ្ណារិទ្ធ | អត្តលេខ ៥៦២៥៧ | នាយរងប៉ុស្តិ៍ |
| ២២-វរសេនីយ៍ទោ | ខុន សុគន្ធ | អត្តលេខ ៦៦៨១៣ | នាយរងប៉ុស្តិ៍ |
| ២៣-វរសេនីយ៍ទោ | លឹម មុន្នីរិទ្ធ | អត្តលេខ ៧៣៨៣៨ | នាយរងប៉ុស្តិ៍ |
| ២៤-វរសេនីយ៍ទោ | ឌី ឧត្តម | អត្តលេខ ៧៦៨៤២ | នាយរងប៉ុស្តិ៍ |
| ២៥-វរសេនីយ៍ទោ | ថៃ សារឿន | អត្តលេខ ៥៤៤៥៣ | នាយផ្នែក |
| ២៦-វរសេនីយ៍ទោ | សោម វណ្ណស៊ី | អត្តលេខ ៩៣០៩៤ | នាយផ្នែក។ |

ខ-មេដាយ **ប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១- ឧត្តមសេនីយ៍ទោ | គឹម សុវណ្ណ | អត្តលេខ ០៤៨៣១ | អនុប្រធាននាយកដ្ឋាន |
| ២- ឧត្តមសេនីយ៍ត្រី | អ៊ុក ប៊ុនច័ន្ទវុធ | អត្តលេខ ០៥៦៨៤ | អនុប្រធាននាយកដ្ឋាន |
| ៣-វរសេនីយ៍ឯក | សោម សារ៉ានី | អត្តលេខ ៦៥៤៥៧ | អនុប្រធាននាយកដ្ឋាន |
| ៤-វរសេនីយ៍ឯក | តេក សុភ័ក្រ | អត្តលេខ ៧៣៥៩៧ | អនុប្រធាននាយកដ្ឋាន |
| ៥-វរសេនីយ៍ទោ | សម្បត្តិ វិសុទ្ធ | អត្តលេខ ៧៧៨៣៨ | នាយរងការិយាល័យ |

| | | | |
|---|---|---|---|
| ៦-វរសេនីយ៍ទោ | សុង គីមជ | អត្តលេខ ៩០៧៥៤ | នាយរងការិយាល័យ |
| ៧-អនុសេនីយ៍ឯក | ឡុង ឆាយហួរ | អត្តលេខ ៨៧៦៨៦ | នាយរងការិយាល័យ |
| ៨-វរសេនីយ៍ឯក | ឈុំ ឈុន | អត្តលេខ ២០៧៣១ | នាយរងប៉ុស្តិ៍ |
| ៩-វរសេនីយ៍ឯក | ឈាង ឈុនដា | អត្តលេខ ៣៨៤០០ | នាយរងប៉ុស្តិ៍ |
| ១០-វរសេនីយ៍ឯក | អ៊ឹម ភីណា | អត្តលេខ ៥៤៩១៥ | នាយរងប៉ុស្តិ៍ |
| ១១-វរសេនីយ៍ត្រី | សេង ពន្លឺ | អត្តលេខ ៧២០៥៧ | នាយរងប៉ុស្តិ៍ |
| ១២-វរសេនីយ៍ត្រី | រ៉ា មុនីរដ្ឋ | អត្តលេខ ៧៨២៤៩ | នាយរងប៉ុស្តិ៍ |
| ១៣-វរសេនីយ៍ត្រី | ញ៉ឹម សោភ័ណ្ឌ | អត្តលេខ ៨៤២៨៣ | នាយរងប៉ុស្តិ៍ |
| ១៤-វរសេនីយ៍ត្រី | កេត សារីសិទ្ធី | អត្តលេខ ៧៧៣៦៦ | នាយផ្នែក |
| ១៥-វរសេនីយ៍ត្រី | សំណាង ទិត្យសត្យា | អត្តលេខ ៧៨៩៨៦ | នាយផ្នែក |
| ១៦-វរសេនីយ៍ត្រី | សេង សាម៉េង | អត្តលេខ ៨៤៣១០ | នាយផ្នែក |
| ១៧-វរសេនីយ៍ត្រី | ម៉ម ចាន់ឌី | អត្តលេខ ៦៩០១៤ | នាយផ្នែក |
| ១៨-វរសេនីយ៍ត្រី | វ៉ាន់ ស៊ីថានវង្ស | អត្តលេខ ៧៤១៥៤ | នាយផ្នែក |
| ១៩-វរសេនីយ៍ត្រី | ហេង ហ្គេចស៊ីម | អត្តលេខ ៧៧៨១០ | នាយផ្នែក |
| ២០-វរសេនីយ៍ត្រី | សេង សុភ័ក្ត្រ | អត្តលេខ ៨៣៣២០ | នាយផ្នែក |
| ២១-វរសេនីយ៍ត្រី | វុឌ្ឍ ផូនាថ | អត្តលេខ ៨៥៥៩៩ | នាយផ្នែក |
| ២២-អនុសេនីយ៍ឯក | ឫទ្ធីពល ពិសិដ្ឋ | អត្តលេខ ៨០០៧៧ | នាយផ្នែក |
| ២៣-អនុសេនីយ៍ត្រី | ថេន ចាន់ណា | អត្តលេខ ៩៨០៦៦ | នាយផ្នែក |
| ២៤-អនុសេនីយ៍ឯក | ម៉ិច មាស | អត្តលេខ ៨៦៩០៤ | នាយរងផ្នែក |
| ២៥-អនុសេនីយ៍ឯក | ឃឹម សុខផាណា | អត្តលេខ ៧៩១៣៣ | នាយរងផ្នែក |
| ២៦-អនុសេនីយ៍ត្រី | លឹម ឆាយគ្រុយ | អត្តលេខ ៩៣២៥៣ | នាយរងផ្នែក |
| ២៧-អនុសេនីយ៍ទោ | ហ៊ិន ភិរម្យ | អត្តលេខ ៩០២៨៧ | មន្ត្រី |
| ២៨-អនុសេនីយ៍ត្រី | ហាក់ ប៊ុនលាង | អត្តលេខ ៩៧៩៦២ | មន្ត្រី |
| ២៩-អនុសេនីយ៍ត្រី | ទិត្យ ស័ក្កដា | អត្តលេខ ៩៤០៧៧ | មន្ត្រី។ |

គ-មេជាយ **សំរឹទ្ធភារខារ**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ត្រី | ម៉ៅ សេរី | អត្តលេខ ៧៩៥៩៥ | នាយរងការិយាល័យ |
| ២-វរសេនីយ៍ត្រី | រស់ ចាន់ណារី | អត្តលេខ ៧៤៧៨០ | នាយផ្នែក |
| ៣- អនុសេនីយ៍ឯក | ឡៀប ប៉ូលីម | អត្តលេខ ៥៤៥៦១ | នាយផ្នែក |
| ៤- អនុសេនីយ៍ឯក | អោ ហ៊ីម | អត្តលេខ ៨៥៩២៨ | នាយផ្នែក |

| | | | |
|---|---|---|---|
| ៥-អនុសេនីយ៍ឯក | ម៉ាត់ អារីហ្វីន | អត្តលេខ ៧៦៧១៣ | នាយផ្នែក |
| ៦-អនុសេនីយ៍ឯក | គង់ ហាងង៉ង | អត្តលេខ ៨៨២៨០ | នាយផ្នែក |
| ៧-អនុសេនីយ៍ឯក | ម៉ម សុផា | អត្តលេខ ៣១៩០៧ | នាយរងផ្នែក |
| ៨-អនុសេនីយ៍ឯក | ព្រាប ពីន | អត្តលេខ ៣៨១២១ | នាយរងផ្នែក |
| ៩-អនុសេនីយ៍ឯក | ឯក ចំរើន | អត្តលេខ ៥៥៦១៧ | នាយរងផ្នែក |
| ១០-អនុសេនីយ៍ឯក | ឡុង ចាន់ថន | អត្តលេខ ៧៦៨១០ | នាយរងផ្នែក |
| ១១-អនុសេនីយ៍ឯក | សោម សាមីឌី | អត្តលេខ ៧៨៤៨០ | នាយរងផ្នែក |
| ១២-អនុសេនីយ៍ឯក | ធៀម សិរីវិសុត | អត្តលេខ ៨០០៩៩ | នាយរងផ្នែក |
| ១៣-អនុសេនីយ៍ឯក | យ៉ង់ ប៊ុនថន | អត្តលេខ ៨៣០១៥ | នាយរងផ្នែក |
| ១៤-អនុសេនីយ៍ទោ | យស ស៊ីឈួន | អត្តលេខ ៨៤៦៧៩ | នាយរងផ្នែក |
| ១៥-អនុសេនីយ៍ទោ | សម្បត្តិ សុភា | អត្តលេខ ៨៧៦៤២ | នាយរងផ្នែក |
| ១៦-ព្រឹន្ទបាលឯក | ស សិទ្ធិឆាយ | អត្តលេខ ៩៣៨៦៥ | នាយរងផ្នែក |
| ១៧-អនុសេនីយ៍ឯក | ម៉ាង ស៊ីណា | អត្តលេខ ៥១១៩៩ | នាយរងផ្នែក |
| ១៨-អនុសេនីយ៍ទោ | តែ ហ៊ុយអាង | អត្តលេខ ៩៨៧៨២ | នាយរងផ្នែក |
| ១៩-អនុសេនីយ៍ត្រី | ម៉ែ ស្រីឌី | អត្តលេខ ៨៩៨៤០ | នាយរងផ្នែក |
| ២០-វរសេនីយ៍ត្រី | អែម សំណាង | អត្តលេខ ៧២៩៣៩ | នាយរងផ្នែក |
| ២១-អនុសេនីយ៍ឯក | ហ៊ិត ឡេង | អត្តលេខ ៦១៧១១ | នាយរងផ្នែក |
| ២២-អនុសេនីយ៍ឯក | ញ៉ឹម ពន្លក | អត្តលេខ ៦៩៧៦១ | នាយរងផ្នែក |
| ២៣-អនុសេនីយ៍ឯក | សន រិទ្ធីវង្សី | អត្តលេខ ៧៦៩៥១ | នាយរងផ្នែក |
| ២៤-អនុសេនីយ៍ឯក | គាត វ័ត្ន | អត្តលេខ ៨៧២៥៦ | នាយរងផ្នែក |
| ២៥-អនុសេនីយ៍ទោ | ដា ដាវឡែន | អត្តលេខ ៩៤១០៦ | នាយរងផ្នែក |
| ២៦-អនុសេនីយ៍ត្រី | ងួន កាណូរ៉ា | អត្តលេខ ៦៩៧៧២ | នាយរងផ្នែក |
| ២៧-អនុសេនីយ៍ឯក | ទឹម កយ | អត្តលេខ ០៦២៦៦ | មន្ត្រី |
| ២៨-អនុសេនីយ៍ឯក | សុខ បូរ៉ាន់ | អត្តលេខ ៣៦៩៩៤ | មន្ត្រី |
| ២៩-អនុសេនីយ៍ឯក | ឈ្នាង ទូច | អត្តលេខ ២៧៣៧៦ | មន្ត្រី |
| ៣០-អនុសេនីយ៍ឯក | ច័ន្ទ ណារ៉េត | អត្តលេខ ៣៤៣៨៩ | មន្ត្រី |
| ៣១-អនុសេនីយ៍ឯក | ទូន ខេមា | អត្តលេខ ៥៥០៤៩ | មន្ត្រី |
| ៣២-អនុសេនីយ៍ឯក | ជា ចេងលីហួរ | អត្តលេខ ៥៧៥៥៤ | មន្ត្រី |
| ៣៣-អនុសេនីយ៍ឯក | ហេង ឆៃណា | អត្តលេខ ៨០៣៧៤ | មន្ត្រី |

| | | | |
|---|---|---|---|
| ៣៤-អនុសេនីយ៍ឯក | ភួង តារាសក្តិ | អត្តលេខ ៨៨៦៣៥ | មន្ត្រី |
| ៣៥-អនុសេនីយ៍ត្រី | ទិត្យ ចំរ៉ុង | អត្តលេខ ៩៤០៧៨ | មន្ត្រី |
| ៣៦-ព្រឹន្ទបាលឯក | ចេន ដារ៉ូ | អត្តលេខ ៨៦៨៩៣ | មន្ត្រី |
| ៣៧-ព្រឹន្ទបាលទោ | វ័ន្ត តារ៉ា | អត្តលេខ ៩១០០៣ | មន្ត្រី។ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤៤៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការ កែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការ កែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើត នាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និងនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១.–**

ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងឧត្តមសេនីយ៍ទោ **ពៅ កល្យាណ** អត្តលេខ ៦៨៦៨៨ ពីអនុប្រធាននាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម ទៅជាអនុប្រធានសេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

**មាត្រា២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៨៨ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពី

## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្ដម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ .–**

ត្រូវបានដាក់មន្ត្រីរាជការចំនួន **០៣ រូប** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម៖

| **ល.រ** | **គោត្តនាម-នាម** | **ឋានន្តរស័ក្តិ និងថ្នាក់** | **ថ្ងៃខែឆ្នាំ ចូលនិវត្តន៍** |
|---|---|---|---|
| ១ | លោកស្រី **អ៊ីង វណ្ណា:** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ១២/៨/២០២៦ |
| ២ | លោក **ជួង សារិន** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | ១៥/៩/២០២៦ |
| ៣ | លោក **ម៉ុត មុររម្យ** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | ៣០/១០/២០២៦ |

**មាត្រា២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៤៥...អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
